**OAKLAND UNIFIED SCHOOL DISTRICT**
សាលារៀនសហគមន៍, សិស្សានុសិស្សចំរុងចំរើន





# សង្កាត់សាលារៀនអូកឡិនដ៍
# មាគ៌ាឆ្ពោះទៅរកឧត្តមភាព • 2015–2020





## កូនសិស្សគ្រប់រូបចំរុងចំរើន!

បានផ្សព្វផ្សាយនៅខែវិច្ឆិកា 2014

# កូនសិស្សគ្រប់រូបចំរុងចំរើន!



19 វិច្ឆិកា 2014

គោរពជូនប្រជាសហគមន៍អូកឡិនដ៍,

ក្នុងនាមជាអ្នកប្រកបរបរអប់រំអស់រយៈពេលម្ភៃឆ្នាំ និងជាឪពុកនៃកូនតូចៗបីនាក់ ខ្ញុំបាទបានបូជាជីវិតពេញវ័យរបស់ខ្ញុំ ជួយទ្រទ្រង់ដល់ការធំធាត់ និងការរីកចំរើននៃកុមារទាំងឡាយ។ ដោយបានបំរើការងារជាគ្រូបង្រៀន ជាចាងហ្វាងសាលារៀន ជាមេដឹកនាំសង្កាត់ ហើយឥឡូវនេះ បានក្លាយជាអគ្គនាយកនៃសង្កាត់សាលារៀនរបស់លោកអ្នក ខ្ញុំបាទមានប្រវត្តិស្នាដៃជោគជ័យក្នុងការងារខាងផ្តល់ឱកាសឱ្យក្មេងជំទង់ៗ, កាត់បន្ថយគន្លាតនៃការសំរេចបានតាមគោលបំណង និងគន្លាតនៃការមានឱកាស រវាងកូនសិស្សដែលមានសាវតាខុសៗគ្នា, លើកស្ទួយប្រតិបត្តិការនៃសាលារៀន តាមការផ្លាស់ប្តូរសាលារៀនានាដែលមានភាពទន់ខ្សោយ និងរៀបចំឱ្យកូនសិស្សជាច្រើននាក់ថែមទៀត បានត្រៀមខ្លួនជាស្រេច ដើម្បីមហាវិទ្យាល័យ ដើម្បីចាប់យកអាជីពអ្វីមួយ និងដើម្បីសហគមន៍។ ការប្តេជ្ញាចិត្តរបស់ខ្ញុំ គឺធ្វើជាដៃគូជាមួយលោកអ្នក ក្នុងការខិតខំប្រឹងប្រែង ដើម្បីធានាយ៉ាងណាឱ្យកូនសិស្សគ្រប់រូប ទទួលបាននូវការអប់រំកំរិតខ្ពស់។ នេះគឺជាមុខរបរប្រកបដោយវិជ្ជាជីវៈ និងជាគោលបំណងផ្ទាល់ខ្លួនរបស់ខ្ញុំ ដែលមាននៅក្នុងលទ្ធិមូលដ្ឋានដែលជោគជ័យរបស់យើងក្នុងការងារនេះ គឺមិនត្រឹមតែសំរាប់សិស្សានុសិស្សក្នុងអូកឡិនដ៍នេះទេ ប៉ុន្តែគឺវាមានផងដែរ នៅក្នុងចំណុចដ៏សំខាន់នៃលទ្ធិប្រជាធិបតេយ្យនៃអាមេរិកាំង។

> The plan before you is our
> **pathway to excellence**
> and the roadmap for the next five years as we uphold our moral obligation to the students and residents of Oakland.

រឿងអាក្រក់ៗជាច្រើនដែលធ្វើឱ្យសង្គមរបស់យើងមានវិបត្តិ អាចស្រាវជ្រាវរកឃើញប្រភពតាមការសង្កេតដ៏ានៃប្រព័ន្ធអប់រំរបស់យើង និងគុណវិបត្តិរបស់ខ្លួន។ នៅពេលដែលយើងពេញចិត្តនឹងភាពល្អបង្គួរ ហើយកូនសិស្សមួយចំនួនធ្វើពុំបានល្អប្រប៉ំផុតនោះ យើងទាំងអស់គ្នា យូរៗទៅ នឹងទទួលបាននូវការខាតបង់។ វាធ្វើឱ្យទីក្រុងរបស់យើង និងប្រទេសជាតិរបស់យើងស្ថិតនៅក្នុងហានិភ័យ។ ចម្លើយចំពោះភាពមិនស៊ីគ្នាទាំងនេះ គឺស្ថិតនៅក្នុងសមត្ថិភាពរបស់យើង ក្នុងផ្លាស់ផ្តូរប្រព័ន្ធអប់រដ្ឋរបស់យើង ដើម្បីឱ្យខ្លួនបំរើកូនសិស្សគ្រប់វណ្ណៈសង្គម និងស្ថានភាពគ្រួសារ និងកំរិតវប្បធម៌ទាំងអស់។ ទស្សនៈវិស័យរបស់យើងនៅអូកឡិនដ៍ គឺចង់បានឱ្យ កូនសិស្សគ្រប់រូប ចំរុងចំរើន! នេះមានន័យថា កូនសិស្សគ្រប់រូប រៀនចប់សាលាហៃស្គូល ដោយក្លាយជាមនុស្សចេះប្រើគំនិតយ៉ាងដិតដល់ ចេះយកចិត្តទុកដាក់ មានសមត្ថភាព មានចំណេះដឹង ក្នុងការត្រៀមខ្លួនជាស្រេច ដើម្បីជោគជ័យពីមហាវិទ្យាល័យ ក្នុងការចាប់យកអាជីពអ្វីមួយ និងដើម្បីសហគមន៍។ ហើយជាមនុស្សដែលចេះធ្វើឱ្យជីវិតមានភាពសប្បាយរីករាយ!

កិច្ចការនេះស្ថិតនៅចំចំណុចប្រសព្វនៃជាតិសាសន៍ ភេទ វណ្ណៈ សាសនា ឋានៈ សិទ្ធិទទួលបានអ្វីមួយ ឱកាស និងការតស៊ូមតិដើម្បីសង្គម – គឺជាសំណួរខ្លះៗដែលធ្វើឱ្យទាស់ចិត្តនៅក្នុងសម័យនេះ ឬនៅក្នុងសម័យណាមួយផ្សេងទៀត។ បើសិនជាយើងត្រូវធ្វើឱ្យគោលដៅរបស់យើងក្លាយជាការពិតសំរាប់កូនៗរបស់យើង និងសង្គមរបស់យើងនោះ យើងត្រូវតែធ្វើឱ្យមានភាពប្រសើរឡើង ទៅលើភាពខុសគ្នានៃប្រជាសាស្ត្រ និងហេតុផលនៃនយោបាយទាំងនេះ ក្នុងការចាប់យកស្តង់ដារកំរិតខ្ពស់ដែលមិនប្រកាន់បក្សពួក – ជាជោគជ័យសំរាប់កូនសិស្សគ្រប់ៗរូប! វាជាការងារដ៏សែនលំបាកខ្លាំងណាស់ ប៉ុន្តែការរកដំណោះស្រាយ គឺមិនលំបាកធ្វើទេ, វាមិនមែនជារឿងអាថ៌កំបាំងអ្វីទេ ហើយវាក៏មិនលំបាកដោះស្រាយដែរ។ ជាការពិតណាស់ ការពិភាក្សាតទល់គ្នាតាមប្រាជ្ញាអំពីវិធីសាស្ត្រ ការបំពេញកិច្ចការបង្រៀន ការផ្តល់ថវិការដ្ឋ និងការស្រឡាញ់មនុស្សជាតិផ្ទាល់ខ្លួន នឹងក្លាយជាកត្តាសំខាន់; ប៉ុន្តែ នៅទីផុតនៃការវិភាគ របៀបដែលយើងអនុវត្តន៍ស្តង់ដារដ៏សំខាន់មួយឈុតនោះ នឹងកំណត់ពីជោគជ័យរបស់យើង។

យើងមានការចាំបាច់តាមផ្លូវសីលធម៌ ក្នុងការជួយឱ្យកុមារគ្រប់រូបសំរេចបាននូវសក្តានុពលរបស់ពួកគេ។ បើសិនជាយើងត្រូវធ្វើយ៉ាងណាឱ្យកូនសិស្សគ្រប់ៗរូបចំរុងចំរើននោះ យើងត្រូវត្រូវតែ ៖

- ផ្តល់ឱ្យកូនសិស្សគ្រប់រូបនូវសិទ្ធិចូលរៀនក្នុងសាលារៀនដែលមានគុណភាពខ្ពស់
- ធានាយ៉ាងណាឱ្យកូនសិស្សម្នាក់ៗត្រៀមខ្លួនជាស្រេច ដើម្បីទទួលជោគជ័យពីមហាវិទ្យាល័យ អាជីព និងសហគមន៍
- ផ្តល់ឱ្យសាលារៀននីមួយៗនូវបុគ្គលិកដែលមានទេពកោសល្យ ដែលប្តេជ្ញាចិត្តធ្វើការបំរើកុមារទាំងឡាយ
- បង្កើតសង្កាត់សាលារៀនមួយ ដែលធ្វើឱ្យខ្លួន និងដៃគូរបស់ខ្លួន ចេះទទួលខុសត្រូវលើការសំរេចឱ្យបាននូវលទ្ធផលល្អប្រសើរ
- ធានាយ៉ាងណាឱ្យមានកម្មវិធីបង្រៀនហ្មត់ចត់ជារៀងរាល់ថ្ងៃ និងនៅគ្រប់ថ្នាក់រៀនទាំងអស់

ការប្តេជ្ញាចិត្តទាំងនេះ មិនអាចចរចារបានទេ; វាជាថ្មស្រទាប់ ដែលយើងនឹងបន្តសាងសង់សង្កាត់នេះនៅលើហ្នឹង។ ខ្ញុំបាទសន្យាថា នឹងខិតខំធ្វើការដោយមិនគិតពីការនឿយហត់ ដើម្បីផ្តល់ឱ្យសិស្សានុសិស្សនៃសង្កាត់សាលារៀនអូកឡិនដ៏ នូវកម្មវិធីអប់រំកំរិតខ្ពស់ និងបទពិសោធន៍ច្រើនគួរជាទីពេញចិត្តសង្គម។ ផែនការនៅចំពោះមុខលោកអ្នកនេះ គឺជាផ្លូវនាំយើងឆ្ពោះទៅរកឧត្តមភាព និងជាផែនទីបង្ហាញផ្លូវសំរាប់ការងារប្រាំឆ្នាំបន្ទាប់មកទៀត នៅពេលដែលយើងកាន់ខ្ជាប់នូវកាតព្វកិច្ចខាងផ្លូវចិត្តរបស់យើង ដើម្បីសិស្សានុសិស្ស និងដើម្បីអ្នកក្រុងអូកឡិនដ៏របស់យើង។

មិនថាទីកន្លែងរបស់លោកអ្នកនៅក្នុងសង្គមអូកឡិនដ៏, មិនថាប្រុស ឬស្ត្រី, ចាស់ទុំ ឬក្មេង, អ្នកស្រុកដើម ឬអ្នកចំណូលថ្មី, អ្នករស់នៅលើតំបន់កណ្តាល ឬអ្នករស់នៅលើតំបន់ភ្នំ គឺយើងទាំងអស់គ្នា សុទ្ធតែមានការជាប់ជំពាក់នឹងការងារនេះ។ មតិយោបល់សមូហភាព និងឯកភាពរបស់យើង ជានិច្ចជាកាលនឹងមានឥទ្ធិពលខ្លាំងក្លាជាងការខិតខំប្រឹងប្រែងជាលក្ខណៈបុគ្គលរបស់យើង។ យើងនឹងឈប់សាកល្បងកម្លាំងគូបដិបក្ខ ឬគិតគូរតែពីបញ្ហារបស់មនុស្សពេញវ័យ ជាងបញ្ហារបស់កូនសិស្ស។ យើងលែងទទួលយកពាក្យថា “ល្អគ្រប់គ្រាន់ហើយ” ទៀតហើយ! យើងត្រូវតែក្លាយទៅជាទីក្រុងមួយ ដែលមានគំរូល្អបំផុត។

គោលការណ៍ណែនាំជំរុញឱ្យគ្រប់ការសម្រេចចិត្ត ដែលខ្ញុំបានធ្វើ ក្នុងនាមជាជាអគ្គនាយកនៃសង្កាត់សាលារៀន, ហើយខ្ញុំនឹងបន្តការខិតខំប្រឹងប្រែងរបស់យើង ឆ្ពោះទៅរកសង្កាត់មួយដែលយើងត្រូវការសំរាប់កូនសិស្សរបស់យើង។ នៅពេលដែលផែនការយុទ្ធសាស្រ្តមានតម្លាភាពហើយនោះ គោលការណ៍គ្រឹះសំរាប់អូកឡិនដ៏ គឺ:

1. គិតពីកូនសិស្សមុនគេបង្អស់
2. សមធម៌
3. សេចក្តីសុចរិត





ការខិតខំប្រឹងប្រែងឥតបង្អង់ដៃតាមគោលការណ៍ណែនាំទាំងនេះ នឹងទទួលបាននូវលទ្ធផលដែលយើងចង់បាន ដោយដាក់បញ្ចូលវាទៅក្នុងទិដ្ឋភាពការងាររបស់យើង។ មិនយូរទៀតទេ យើងនឹងលែងអនុញ្ញាតឱ្យមានពាក្យថា “មាន” និង “គ្មាន” ជាអ្នកកំណត់អូកឡិនដ៏ទៀតហើយ។ ផ្ទុយទៅវិញ យើងនឹងសរសេររៀបរាប់បែបថ្មីអំពីសហគមន៍ដ៏រឹងមាំ និងអំពីការបំរើសេវាដល់ដល់កូនសិស្ស។ យើងនឹងធ្វើឱ្យសង្កាត់សាលារៀនអូកឡិនដ៏ ជាទីកន្លែងធ្វើការមួយដែលគេចង់ចូលមកធ្វើការ និងជាអ្នកផ្តល់ប្រព័ន្ធអប់រំលំដាប់ពិភពលោក។ នៅពេលយើងចាប់ផ្តើមធ្វើដំណើរនេះ យើងត្រូវតែស្វែងរកផលប្រយោជន៍រួម ក្នុងការផ្តល់ការអប់រំមួយដែលធ្វើឱ្យកូនសិស្សខិតខំអស់ពីសមត្ថភាព, ជំរុញឱ្យពួកគេចេះគិត, លើកទឹកចិត្តឱ្យពួកគេចេះបង្កើតអ្វីមួយ, ញុាំចិត្តពួកគេឱ្យចេះស្រមើស្រមៃ, ជួយឱ្យពួកគេទទួលបានជោគជ័យ និងរៀបចំឱ្យពួកគេ មិនត្រឹមតែសម្រាប់មហាវិទ្យាល័យ និងអាជីពនោះទេ ប៉ុន្តែសម្រាប់ពិភពលោកទាំងមូល។ ខ្ញុំបាទទទឹងរង់ចាំធ្វើជាដៃគូជាមួយលោកអ្នកក្នុងកិច្ចការនេះ ហើយកូនសិស្សរបស់យើង មិនអាចរង់ចាំលទ្ធផលរបស់ខ្លួនឡើយ។ ថ្ងៃណាមួយក្នុងអនាគត កន្លែងណាមួយនៅក្នុងប្រទេសអាមេរិក សង្កាត់សាលារៀនណាមួយ និងទីក្រុងណាមួយ នឹងបំពេញកាតព្វកិច្ចរបស់ខ្លួនដើម្បីកុមាររបស់ខ្លួន។ ចុះយើងចាំដល់ពេលណាទៀត? ហេតុអ្វីមិនធ្វើនៅទីក្រុងអូកឡិនដ៏?

នេះគឺជាពេលត្រូវធ្វើហើយ។ នេះគឺជាទីកន្លែងដែលយើងត្រូវធ្វើហើយ។ នេះគឺជាពេលដែលយើងមករួបរួមគ្នាដើម្បីធ្វើយ៉ាងណាឱ្យ កូនសិស្សគ្រប់រូប ចំរុងចំរើន!

ដោយក្តីគោរពយ៉ាងស្មោះពីខ្ញុំ,



Antwan Wilson
អគ្គនាយកនៃសង្កាត់សាលារៀន

## គោលបំណង៖

ក្លាយជាសង្កាត់សហាគមន៍បំរើសេវាទូលំទូលាយ ដែលផ្តោតជាសំខាន់លើការសំរេចបានជោគជ័យក្នុងការសិក្សាមុខវិជ្ជាសិក្សាកំរិតខ្ពស់ ខណៈដែលបំរើកុមារទាំងស្រុងលុបបំបាត់ចោលនូវភាពមិនស្មើគ្នា និងផ្តល់ឱ្យកូនសិស្សម្នាក់ៗនូវគ្រូបង្រៀនដ៏ល្អប្រសើរជារៀងរាល់ថ្ងៃ។

## ទស្សនៈវិស័យ៖

កូនសិស្សគ្រប់រូប ចំរុងចំរើន! នេះមានន័យថា កូនសិស្សគ្រប់រូប រៀនចប់សាលាហៃស្កូល ដោយក្លាយជាមនុស្សចេះប្រើគំនិតយ៉ាំងដិតដល់ ចេះយកចិត្តទុកដាក់ មានសមត្ថភាព មានចំណេះដឹង ក្នុងការត្រៀមខ្លួនជាស្រេច ដើម្បីជោគជ័យពីមហាវិទ្យាល័យ ពីការចាប់យកអាជីពអ្វីមួយ និងដើម្បីសហាគមន៍។ ហើយជាមនុស្សដែលចេះធ្វើឱ្យជីវិតមានភាពសប្បាយរីករាយ!



## តាមរបៀបអ្នកអូកឡិនដ៍!

ធានាយ៉ាងណាឱ្យកុមារម្នាក់ៗ និងគ្រប់ៗរូប ទទួលបាននូវការអប់រំដែលមានគុណភាព គឺជាសេដ្ឋកិច្ចដ៏ចាំបាច់ ជាសីលធម៌ចាំបាច់ត្រូវបំពេញ ហើយវាជាបញ្ហាយុត្តិធម៌សំរាប់សង្គម។ ហ្នឹងគឺជារឿងដែលសហាគមន៍នេះយល់ច្បាស់ជាងទីប្រជុំជនណាមួយផ្សេងៗទៀតទាំងអស់នៅក្នុងសហរដ្ឋអាមេរិក។ អស់រយៈពេលច្រើនជាង 60 ឆ្នាំហើយ អូកឡិនដ៍បានក្លាយជាអ្នកត្រួសត្រាយបញ្ហាសមធម៌ និងការផ្តល់លទ្ធភាព ហើយជាទីកន្លែងសំខាន់នៃចលនាដ៏មានឥទ្ធិពលបំផុតដើម្បីសង្គមមួយចំនួននៅក្នុងប្រទេស។ យើងគឺជាអ្នកដឹកនាំក្រុមយុទ្ធនាការ។ គ្មានការអ្វីល្អជាងការតស៊ូដើម្បីជួយកុមាររបស់យើងនោះទេ។

**បន្ទុករបស់យើងគឺធ្វើការផ្លាស់ប្តូរប្រព័ន្ធអប់រំសាលារដ្ឋមួយដែលបង្រួមការបែងចែកជាតិសាសន៍ និងវណ្ណៈឱ្យទៅជាសង្គមតែមួយដែលទម្លុះទម្លាយចោលនូវឧបសគ្គ ដែលរារាំងដល់ការសំរេចបានជោគជ័យ និងដើម្បីរៀបចំឱ្យកូនសិស្សគ្រប់រូបត្រៀមខ្លួនសំរាប់មហាវិទ្យាល័យ អាជីព និងសហាគមន៍។**

អូកឡិនដ៍គឺជាទីក្រុងមួយ ដែលជាយូរមកហើយ ត្រូវបានគេកំណត់ន័យយ៉ាងច្បាស់លាស់ដោយពាក្យថា ‹មានសក្តានុពល›។ វាជាពេលត្រូវផ្លាស់ប្តូរការមានសក្តានុពលមកជាការមានលទ្ធផលហើយ និងត្រូវធានាយ៉ាងណាឱ្យ ‹កូនសិស្សគ្រប់រូបចំរុងចំរើន!›។ ក្នុងនាមជាសហាគមន៍ វាជាកាតព្វកិច្ចរបស់យើង ក្នុងការធ្វើឱ្យការសន្យាចំពោះអូកឡិនដ៍ក្លាយជាការពិត។ ក្នុងនាមជាសង្កាត់សាលារៀន វាជាទំនួលខុសត្រូវរបស់យើង - ហើយជាឯកសិទ្ធរបស់យើង - ក្នុងការរៀបចំឱ្យកូនសិស្សគ្រប់រូបទទួលបានជោគជ័យក្នុងការសិក្សា ជោគជ័យក្នុងការចាប់យកអាជីពអ្វីមួយ និងជោគជ័យក្នុងឆាកជីវិត។ ភាពត្រូវការធ្វើជាបន្ទាន់នេះគឺមានលក្ខណៈធំធេងណាស់។ យើងមិនមានពេលវេលាខ្ជះខ្ជាយទេ ហើយយើងក៏មិនមានពេលវេលារង់ចាំយូរតទៅទៀតដែរ។ មានតែតាមការមិនទទួលយកនូវភាពល្អបង្គួរ ការមិនទទួលយកនូវការរំពឹងទុកដែលមានកំរិតទាប និងបង្កើតស្តង់ដារម៉ឺងម៉ាត់សំរាប់ប្រតិបត្តិការទេ ដែលយើងអាចផ្តល់ឱ្យកូនៗរបស់យើងនូវការអប់រំដែលពួកគេសមនឹងទទួលបាន និងបង្កើតសហាគមន៍ដែលយើងប្រាថ្នាចង់បាន។

“ជំនឿរបស់យើង គឺថាការធ្វើឱ្យលទ្ធផលនៃកូនសិស្សមានភាពប្រសើរឡើងគួរជាទីកត់សំគាល់ ត្រូវបានជំរុញឱ្យធ្វើនៅថ្នាក់សាលារៀន។ រាល់សកម្មភាពរបស់យើង ជាសំខាន់ គឺធ្វើដើម្បីគោលបំណងតែមួយ៖ ការបង្កើតសាលារៀនសហាគមន៍ដែលមានគុណភាព ដែលរៀបចំឱ្យកូនសិស្សទទួលបានជោគជ័យពីមហាវិទ្យាល័យ អាជីព និងសហាគមន៍។ សហាគមន៍សាលារៀននានាដែលមានសិទ្ធិអំណាចធានាខុសត្រូវ ដែលធ្វើកិច្ចសំរេចចិត្តឱ្យត្រូវនឹងសេចក្តីត្រូវការនៃកុមារណាមួយ, សម្របកម្មវិធីបង្រៀនឱ្យត្រូវនឹងការប្រកបវិជ្ជាជីវៈដ៏មានប្រសិទ្ធភាព, វាស់ស្ទង់ឱ្យបានញឹកញាប់ទៅលើការរីកចំរើនខាងការសិក្សាមុខវិជ្ជាសិក្សា និងសង្គម និងសម្របសម្រួលតាមការចាំបាច់ ដើម្បីបង្កើនការរៀនសូត្ររបស់កូនសិស្ស គឺជាមូលដ្ឋាននៃសង្កាត់លំដាប់ពិភពលោក។ សាលារៀនទាំងអស់ នឹងទទួលបាននូវផលប្រយោជន៍ពីស្នាដៃរបស់យើង ក្នុងការជ្រើសរើសសមាជិកថ្មី ក្នុងការបង្កើត និងក្នុងការរក្សាទុកឱ្យបានគង់វង់នៅគ្រប់ថ្នាក់រៀនទាំងអស់ និងនៅគ្រប់នាយកដ្ឋានទាំងអស់ នូវបុគ្គលិកដែលមានទេពកោសល្យ។ សាលារៀនទាំងអស់នឹងទទួលបាននូវស្វ័យភាព ការជួយជ្រោមជ្រែង និងការទទួលស្គាល់ច្បាស់លាស់ - ក៏ដូចគ្នាដែរ នូវការជួយធ្វើអន្តរាគមន៍ចំគោលដៅ - ដើម្បីធ្វើឱ្យការបំពេញកិច្ចការសិក្សារបស់កូនសិស្សឱ្យមានភាពប្រសើរឡើង។ ហើយនៅពេលណាសាលារៀន ពុំអាចបង្ហាញឱ្យឃើញថាខ្លួនមានសមត្ថភាពគ្រប់គ្រងខ្លួនឯងឱ្យបានមាំមួន ឬបង្ហាញឱ្យឃើញថាកូនសិស្សរបស់ខ្លួនមានការរីកចំរើនខ្លាំងក្នុងការសិក្សាមុខវិជ្ជាសិក្សា និងសង្គម ក្នុងរយៈពេលណាមួយនោះ យើងនឹងធ្វើអន្តរាគមន៍ជួយពន្លឿននូវការរៀនសូត្ររបស់កូនសិស្ស, លើកស្ទួយគុណភាពសាលារៀន និងធានាយ៉ាងណាឱ្យ ‹កូនសិស្សគ្រប់រូបចំរុងចំរើន!›។

# អាទិភាពទី 1

## កម្មវិធីសំរាប់អ្នកមានទេពកោសល្យជាក់ស្តែង

### ការងាររបស់យើងគឺចាប់ផ្តើមជាមួយនឹងមនុស្សរបស់យើងតែម្តង។

យើងត្រូវការធ្វើឱ្យសង្កាត់សាលារៀនអ្នកឡិនដ៍ ជានិយោជកដ៏ល្អប្រសើរនៅក្នុងតំបន់ឆកសម្បុទ្រ។ នេះមានន័យថា យើងត្រូវតែរកជ្រើសរើសបុគ្គលិកថ្មីៗដែលមានទេពកោសល្យ, បង្កើតប្រព័ន្ធមួយដែលបណ្តុះបណ្តាលឱ្យពួកគេមានការរីកចំរើន និងបង្កើតវប្បធម៌មួយដែលជួយរក្សាទុកនូវនិយោជិកដ៏មានប្រសិទ្ធភាពខ្ពស់។

- ឱ្យបានមុនឆ្នាំ 2010 ចំនួននិយោជិកដែលចូលរួមយ៉ាងខ្លាំងជាមួយនឹងសង្កាត់សាលារៀនអ្នកឡិនដ៍ ដូចបានវាស់ស្ទង់ដោយកម្មវិធីទាក់ទាញមនុស្សឱ្យមកចូលរួមរបស់យើង នឹងមានកំណើនកើនឡើងដល់ទៅ 85%។

គោលដៅ





### និយោជិកបានចូលរួម

2020............... 85%

ឥឡូវនេះ........ បច្ចុប្បន្ននេះ:
យើងខ្ញុំពុំទាន់បានវាស់ស្ទង់ទេ

# អាទិភាពទី 2

## សង្កាត់សាលារៀនដែលមានទំនួលខុសត្រូវ

### សង្កាត់សាលារៀនមួយដែលជួយទ្រទ្រង់មនុស្សរបស់ខ្លួន

ដោយផ្តែកលើគុណតម្លៃ និងប្រព័ន្ធដ៏មានប្រសិទ្ធភាព។ យើងនឹងធានាថា យើងនឹងក្លាយជាក្រុមមនុស្សតែមួយដែលបានប្តូជាកម្លាំងកាយក្នុងការបង្កើតសាលារៀនដ៏មានប្រសិទ្ធភាពនៅគ្រប់សង្កាត់ជិតខាងទាំងអស់នៃអ្នកឡិនដ៍។ យើងនឹងផ្តល់ការបំរើសេវាដែលគួរឱ្យគេយកគំរូតាម ដល់សាលារៀនទាំងអស់នៅក្នុងទីក្រុងអ្នកឡិនដ៍ ដោយសង្កត់ធ្ងន់លើការបង្កើនសមិទ្ធផល និងការចូលរួមសំរាប់សិស្សានុសិស្សនៃយើង។

- ឱ្យបានមុនឆ្នាំ 2020 ចំនួនសាលារៀនដ៏មានគុណភាពខ្ពស់ៗ ហើយដែលទទួលបានលទ្ធផលខ្ពស់ៗ ដូចបានវាស់ស្ទង់ដោយគំរោងប្រតិបត្តិការនៃសាលារៀនរបស់សង្កាត់ នឹងកើនឡើងដល់ទៅ 75%។
- ឱ្យបានមុនឆ្នាំ 2020 យ៉ាងហោចណាស់ 80% នៃអ្នកឆ្លើយតបតាមការសិក្សាស្រាវជ្រាវមតិអំពីការគ្រប់គ្រងលើប្រតិបត្តិការរបស់សង្កាត់សាលារៀនអ្នកឡិនដ៍ នឹងឱ្យតម្លៃដល់នាយកដ្ឋាននានានៃសង្កាត់ នូវការអនុម័តយល់ព្រម។

គោលដៅ





### សាលារៀនដ៏មានគុណភាព និងទទួលបាននូវលទ្ធផលខ្ពស់

2020............... 75%

ឥឡូវនេះ........ បច្ចុប្បន្ននេះ:
យើងខ្ញុំពុំទាន់បានវាស់ស្ទង់ទេ

### នាយកដ្ឋាននានានៃសង្កាត់ប្រតិបត្តិបាន នូវការអនុម័តយល់ព្រម

2020............... 80%

ឥឡូវនេះ........ បច្ចុប្បន្ននេះ:
យើងខ្ញុំពុំទាន់បានវាស់ស្ទង់ទេ

# អាទិភាពទី 3

## សាលារៀនសហគមន៍ដែលមានគុណភាព

**រាល់កូនសិស្សគ្រប់រូបមានសិទ្ធិចូលរៀនក្នុងសាលារៀនសហគមន៍ដែលមានគុណភាពនៅក្នុងសង្កាត់ជិតខាងរបស់ពួកគេ។** កិច្ចការនៃសាលារៀនសហគមន៍ក្នុងក្រុងអូកឡិនដ៍ គឺជាកិច្ចការមួយចំនួនដែលធ្វើឱ្យមានការយកចិត្តទុកដាក់បំផុតនៅក្នុងប្រទេស។ តាមការផ្តោតជាសំខាន់លើវិធីសាស្រ្តដ៏សំខាន់ៗខ្លះៗ យើងនឹងបង្កើតសាលារៀនផ្សេងៗដែលកូនសិស្សទាំងអស់នៅក្នុងតំបន់ឆកសមុទ្រយើងនេះពេញចិត្តមកចូលរៀន។

- ឱ្យបានមុនឆ្នាំ 2020 ចំនួនភាគរយនៃកូនសិស្សសាលាហៃស្កូលនៅក្នុងកម្មវិធី Linked Learning Pathways នឹងកើនឡើងដល់ទៅ 80% ហើយ 100% សំរាប់កូនសិស្សដែលនឹងឡើងទៅថ្នាក់ទី៨ដប់។
- ឱ្យបានមុនឆ្នាំ 2020 អត្រានៃក្រុមកូនសិស្សដែលត្រូវរៀនចប់ នឹងកើនឡើងដល់ទៅ 85%។
- ឱ្យបានមុនឆ្នាំ **2020** ចំនួនភាគរយនៃកូនសិស្សអាហ្វ្រិកអាមេរិកាំង កូនសិស្សឡាទីន កូនសិស្សអប់រំពិសេស កូនសិស្សអ្នករៀនភាសាអង់គ្លេស (ELL) និងយុវសិស្សដែលជាកូនចិញ្ចឹម ណាដែលបំពេញបានទៅតាមតម្រូវការនានានៃហាវិទ្យាល័យនៃរដ្ឋកាលីហ្វូនញ៉ា សំរាប់មហាវិទ្យាល័យ ឬសកលវិទ្យាល័យបួនឆ្នាំនោះ នឹងកើនឡើងដល់ **60** ភាគរយ។
- ឱ្យបានមុនឆ្នាំ 2020 ចំនួនភាគរយនៃកូនសិស្សអ្នករៀនភាសាអង់គ្លេសក្នុងរយៈពេលវែង (6 ឡើងទៅនៅក្នុងសាលារៀនសហរដ្ឋ) ដែលនឹងត្រូវបានចាត់ថ្នាក់ឡើងវិញថាជាកូនសិស្សចេះស្ទាត់ខាងភាសាអង់គ្លេស នឹងមានការកើនឡើងដល់ទៅ 50%។
- ឱ្យបានមុនឆ្នាំ 2020 ចំនួនភាគរយនៃកូនសិស្សប្រុសអាហ្វ្រិកអាវិកាំង ដែលពុំត្រូវបានបញ្ឈប់បណ្តោះអាសន្នពីសាលារៀននៅក្នុងឆ្នាំសិក្សា នឹងមានការកើនឡើងដល់ទៅ 97%។
- ឱ្យបានមុនឆ្នាំ 2020 ចំនួនភាគរយនៃកូនសិស្សថ្នាក់ទី 3 ដែលចេះអានស្មើនឹងកំរិតថ្នាក់ នឹងមានការកើនឡើងដល់ទៅ 85%។

**គោលដៅ**



កូនសិស្សហៃស្កូលចូលក្នុងកម្មវិធី Linked Learning Pathways

2020................. 80%

ឥឡូវនេះ.......... 37%



High School Sophomores in កូនសិស្សថ្នាក់ទី៨ដប់នៃសាលាស្កូលចូលកម្មវិធី Linked Learning Pathways

2020................. 100%

ឥឡូវនេះ.......... 47%




កូនសិស្សអាហ្វ្រិកអាមេរិកាំង កូនសិស្សឡាទីន កូនសិស្សអប់រំពិសេស កូនសិស្សអ្នករៀនភាសាអង់គ្លេស (ELL) និងយុវសិស្សដែលជាកូនចិញ្ចឹម ដែលបំពេញបានទៅតាមតម្រូវការនានាសំរាប់មហាវិទ្យាល័យ ឬសកលវិទ្យាល័យបួនឆ្នាំ។

2020................. 60%

ឥឡូវនេះ.......... 23%

**គោលដៅ**



អត្រាក្រុមកូនសិស្សរៀនចប់ពីសាលាហៃស្កូល

2020................. 85%

ឥឡូវនេះ.......... 67%



កូនសិស្សអ្នករៀនភាសាអង់គ្លេសក្នុងរយៈពេលវែង និងត្រូវបានចាត់ថ្នាក់សាជាថ្មីថាជាកូនសិស្សចេះស្ទាត់ភាសាអង់គ្លេស

2020................. 50%

ឥឡូវនេះ.......... 7%



កូនសិស្សប្រុសអាហ្វ្រិកអាមេរិកាំងដែលពុំមានការបញ្ឈប់បណ្តោះអាសន្នពីសាលារៀន

2020................. 97%

ឥឡូវនេះ.......... 87%



កូនសិស្សថ្នាក់ទី 3 ចេះអានស្មើនឹងកំរិតថ្នាក់

2020................. 85%

ឥឡូវនេះ.......... 38%

| អាទិភាពទី | វិធីសាស្ត្រនានា |
|---|---|



## កម្មវិធីសំរាប់អ្នកមានទេពកោសល្យជាក់ស្តែង

### ការជ្រើសរើសបុគ្គលិកថ្មី និងការផ្តល់តំណែង
យើងនឹងផ្តោតជាសំខាន់លើការជ្រើសរើសបុគ្គលិកថ្មីៗ ដែលមានទេពកោសល្យ និងរៀបចំប្រព័ន្ធដ៏មានប្រសិទ្ធភាព សំរាប់ជួយទ្រទ្រង់ដល់ការផ្លាស់ប្តូររបស់ពួកគេប្រកបដោយជោគជ័យក្នុងតួនាទីរបស់ពួកគេនៅក្នុងសង្កាត់។

### ការជួយជ្រោមជ្រែង និងការវាយតម្លៃ
យើងនឹងធ្វើឱ្យសង្កាត់សាលារៀនអូកឡិនដ៍ ជាទីកន្លែងការងារដ៏ល្អដែលគេចង់មកធ្វើការ នៅក្នុងតំបន់ឆកសមុទ្រ តាមការបង្កើតលក្ខខណ្ឌនានាសំរាប់ជោគជ័យតាមរយៈក្រុមដ៏មានប្រសិទ្ធភាព ,វប្បធម៌នៃការរៀនសូត្រពីគ្នាទៅវិញទៅមកប្រកបដោយវិជ្ជាជីវៈ និងការប្រើការកត់សំគាល់ និងការផ្តល់មតិយោបល់ដើម្បីស្ថាបនា។

### ការដឹកនាំ និងការរក្សាទុកឱ្យបានគង់វង់
យើងនឹងបង្កើតឱកាសរីកចំរើនប្រកបដោយវិជ្ជាជីវៈ ដែលជួយដល់ការបណ្តុះបណ្តាលនិយោជិក ក្នុងនាមជាអ្នកអប់រំ និងជាមេដឹកនាំ នៅក្នុងប្រព័ន្ធរបស់យើង ក្នុងលក្ខណៈមួយដែលជួយទ្រទ្រង់ដល់ការរកការងារឱ្យនិយោជិកដ៏មានប្រសិទ្ធភាព និងការរក្សាទុកពួកគេឱ្យបានគង់វង់។



## សង្កាត់សាលារៀនដែលមានទំនួលខុសត្រូវ

### ការអនុវត្តគុណតម្លៃស្នូលនៃសង្កាត់
យើងនឹងរៀបចំបង្កើតរួមគ្នានូវគុណតម្លៃស្នូលរបស់សង្កាត់មួយឈុត ដែលនឹងត្រូវបានប្រើប្រាស់ក្នុងការនាំផ្លូវពីរបៀបដែលយើងជួយគាំពារនិយោជិករបស់យើង, ចូលរួមជាមួយក្រុមគ្រួសារ និងសហគមន៍របស់យើង និងផ្តល់សេវានានាដល់កូនសិស្សរបស់យើង។ គុណតម្លៃស្នូលទាំងនេះ គឺមានបំណងធ្វើឱ្យវប្បធម៌របស់យើងជ្រួតជ្រាប និងត្រូវបានប្រើប្រាស់ដើម្បីនាំយើងឆ្ពោះទៅកាន់គោលដៅចំបងរបស់យើង ក្នុងនាមជាសង្កាត់សាលារៀន។

### ការបង្កើតសាលារៀនដែលមានគុណភាព
យើងនឹងចូលរួមក្នុងការវិភាគតាមវិធីសាស្ត្រនៃតំបន់ ដើម្បីផ្តល់ដំណឹងប្រាប់ពីកន្លែងដែលយើងត្រូវការកម្មវិធីដែលមានគុណភាពថែមទៀត និងដើម្បីប្រាប់ពីទីកន្លែងអាគារនានារបស់សង្កាត់ដែលត្រូវការប្រើប្រាស់ឱ្យមានប្រសិទ្ធភាពថែមទៀត។ ក្រៅពីនេះ យើងនឹងបង្កើតគំរោងប្រតិបត្តិការសាលារៀនមួយ ទុកវាស់ស្ទង់គុណភាពនៅតាមទីសាលារៀននីមួយៗទាំងអស់។ ទីបញ្ចប់ យើងនឹងចាប់ផ្តើមការអំពាវនាវឱ្យសាលារៀនដែលមានគុណភាពផ្តោតជាសំខាន់លើការជួយបង្កើតគំរូសាលារៀនដែលមានប្រសិទ្ធភាពចាប់ពីទាបឡើងទៅ និងដើម្បីធានាយ៉ាងឱ្យកូនសិស្សគ្រប់រូបអាចទៅរៀនសាលារៀនដែលមានគុណភាពនៅក្នុងសង្កាត់ជិតខាងរបស់ពួកគេ។

### កិច្ចព្រមព្រៀងនៃសាលាឆាតធើស្គូលនៃសង្កាត់
យើងនឹងចាប់ដៃគូជាមួយសាលាឆាធើស្គូល ដើម្បីផ្តល់សិទ្ធិប្រើប្រាស់សាលារៀនដែលមានគុណភាពនៅគ្រប់សង្កាត់ជិតខាងទាំងអស់ ទទឹមនឹងការបង្កើតប្រព័ន្ធរួមសំរាប់ការចុះឈ្មោះរៀន ការផ្ទេរសាលា ការដាក់វិន័យ ការបំពេញកិច្ចការសិក្សា និងបំរើកូនសិស្សទាំងអស់នៃក្រុងអូកឡិនដ៍។

### ការគ្រប់គ្រងប្រតិបត្តិការ
យើងនឹងវាស់ស្ទង់ប្រសិទ្ធភាពនៃការបំរើសេវាពីការិយាល័យកណ្តាល ដើម្បីធានាយ៉ាងណាឱ្យសេចក្តីត្រូវការរបស់កូនសិស្សត្រូវបានយកចិត្តទុកដាក់មុនគេបង្អស់ ហើយថាសាលារៀននានាទទួលបាននូវការជួយគាំពារដែលពួកគេត្រូវការដើម្បីឱ្យបានសំរេចជោគជ័យ។ យើងនឹងចូលរួមក្នុងខួបនៃការសាកសួរព័ត៌មាន ដើម្បីលើកកម្ពស់នៃសេវាកម្មគំរូ និងដើម្បីកែលំអផ្នែកជួយគាំពាររបស់យើងដល់អ្នកចូលរួមទាំងឡាយរបស់យើង។



## សាលារៀនសហគមន៍ដែលមានគុណភាព

### កម្មវិធីសិក្សា LINKED LEARNING
យើងនឹងផ្តល់ឱកាសសរៀនសូត្រសំរាប់កូនសិស្សទាំងអស់របស់យើង ដែលបំពេញតាមស្តង់ដារត្រៀមខ្លួនជាស្រេចដើម្បីមហាវិទ្យាល័យ និងអាជីព, ផ្តល់ការរៀនសូត្រតាមបទពិសោធន៍ និងដាក់បញ្ចូលនូវការរៀនតាមគ្រឿងបច្ចេកទេស ដើម្បីធានាយ៉ាងណាឱ្យកូនសិស្សត្រៀមខ្លួនដើម្បីឱ្យសំរេចបានជោគជ័យពីមហាវិទ្យាល័យ អាជីព និងសហគមន៍។ នេះនឹងចាប់ពីកម្មវិធីអប់រំសំរាប់កុមារតូច ដើម្បីធានាយ៉ាងឱ្យកូនសិស្សត្រៀមខ្លួនសំរេចឱ្យបានជោគជ័យនៅថ្នាក់ទីបី។ វាបន្តផ្តោតជាសំខាន់លើការយកចិត្តទុកដាក់ថែមទៀតតាមការកែលំអមធ្យមសិក្សារបស់យើង តាមការដាក់បញ្ចូលនូវកម្មវិធីបង្ហាញមុខវិជ្ជាដែលរៀបចំកូនសិស្សឱ្យទទួលបានជោគជ័យពីការចាប់យកអាជីពក្នុងវិស័យវិទ្យាសាស្ត្រ បច្ចេកទេស វិស្វកម្ម សិល្បៈ គណិតសាស្ត្រ សុខភាព និងវិស័យសហគ្រិន។ កម្មវិធីបង្ហាញមុខវិជ្ជាតាម Linked Learning នឹងតម្រូវឱ្យកូនសិស្សចូលធ្វើតេស្តសំរាប់ថ្នាក់រៀនមុខវិជ្ជាកំរិតខ្ពស់នៃមហាវិទ្យាល័យ, ថ្នាក់រៀនបរិញ្ញាត្រីអន្តរជាតិ នឹង/ឬ ថ្នាក់រៀនមុខវិជ្ជាកំរិតមហាវិទ្យាល័យខណៈកំពុងរៀននៅសាលាហៃស្គូល ទទឹមនឹងការផ្តល់ជំនួយដល់កូនសិស្សណាដែលត្រូវការបំពេញតាមការរំពឹងទុកកំរិតមហាវិទ្យាល័យ និងអាជីព។

### កម្មវិធីអប់រំផ្អែកលើសមធម៌
យើងនឹងជួយជ្រោមជ្រែងសាលារៀនយើងតាមការអនុវត្តន៍វិធីសាស្ត្រនានាដែលពន្លឿនសមិទ្ធផលនៃការសិក្សាមុខវិជ្ជាសិក្សានៃកូនសិស្សទាំងអស់ ទទឹមនឹងការធ្វើយ៉ាងណាឱ្យយើងធ្វើការភ្ជិតគន្លាតមានឱកាសសំរាប់កូនសិស្សអាហ្វ្រិកអាមេរិកាំង កូនសិស្សអ្នករៀនភាសាអង់គ្លេស យុវសិស្សដែលជាកូនចញ្ចឹម និងកូនសិស្សនៃកម្មវិធីអប់រំពិសេស។ នេះរួមមានទាំងការប្រើវឌ្ឍនភាពនៃសមិទ្ធផលនៃកូនសិស្សប្រុសអាហ្វ្រិកអាមេរិកាំង ទុកជាមូលដ្ឋានសំរាប់ការរីកចំរើនថែមទៀត; ហើយវាមានបញ្ចូលផងដែរនូវការផ្តល់ធនធាន និងការជួយជ្រោមជ្រែងថែមទៀតដល់សាលារៀនមួយចំនួន ដើម្បីលើកស្ទួយជោគជ័យនៃកូនសិស្សរបស់យើងដែលត្រូវប៉ះពាល់យ៉ាងខ្លាំងជាងគេ ដែលទិន្នន័យរបស់យើងបង្ហាញឱ្យឃើញថាយើងត្រូវការធ្វើថែមទៀត ដើម្បីជួយឱ្យសំរេចបាននូវលទ្ធផលក្នុងការសិក្សាមុខវិជ្ជាសិក្សាកំរិតខ្ពស់។

### ការគ្រប់គ្រងទីសាលារៀន
យើងនឹងផ្តោតជាសំខាន់លើការចូលរួមដែលមានលក្ខណៈច្បាស់លាស់ មានតម្លាភាព និងមានតំណាងដែលផ្តល់លទ្ធភាពដល់អ្នកចូលរួម ក្នុងការធ្វើការរួមគ្នាជាមួយនឹងចាងហ្វាងសាលារៀន ដើម្បីកែលំអលទ្ធផលនៃការអប់រំសំរាប់កូនសិស្សទាំងអស់។ នេះនឹងមានដាក់បញ្ចូលនូវការធ្វើអាទិភាពដល់វិធីកែលំអសំដៅទៅលើសេចក្តីត្រូវការនៃកូនសិស្សដែលសាលារៀនបំរើ ហើយដែលសម្របយ៉ាងតឹងរ៉ឹងជាមួយនឹងអាទិភាពនានារបស់សង្កាត់។

# រូបមន្តផ្តល់ថវិកាសំរាប់ការគ្រប់គ្រងថ្នាក់មូលដ្ឋាន (LCFF) | ផែនការទទួលខុសត្រូវនៃការគ្រប់គ្រងថ្នាក់មូលដ្ឋាន (LCAP)



ដើម្បីធានាឱ្យកូនសិស្សគ្រប់រូបនៃសង្កាត់សាលារៀនអូកឡិនដ៍ ត្រៀមខ្លួនទទួលបានជោគជ័យពីមហាវិទ្យាល័យ អាជីព និងសហគមន៍នោះ យើងត្រូវតែប្រើធនធានទាំងអស់ដែលយើងអាចប្រើការបាន ហើយនឹងលៃវាទុកក្នុងលក្ខណៈមួយដែលឆ្លុះបញ្ចាំងពីជំនឿរបស់យើង និងជួយទ្រទ្រង់ទស្សនវិស័យតែមួយសំរាប់កូនសិស្សសាលាអូកឡិនដ៍។

- រូបមន្តផ្តល់ថវិកាសំរាប់ការគ្រប់គ្រងថ្នាក់មូលដ្ឋាន (LCFF) កំណត់របៀបដែលរដ្ឋផ្តល់ថវិកាដល់សង្កាត់សាលារៀនរបស់យើង។ ប្រាក់កាសត្រូវបានលៃទុកតាមចំនួនចុះឈ្មោះរៀននៃកូនសិស្សអ្នករៀនភាសាអង់គ្លេស, កូនសិស្សនៃក្រុមគ្រួសារដែលមានប្រាក់ចំណូលទាប និងកូនសិស្សដែលជាកូនចិញ្ចឹម។
- ផែនការទទួលខុសត្រូវនៃការគ្រប់គ្រងថ្នាក់មូលដ្ឋាន (LCAP) គឺជាផែនការទទួលខុសត្រូវ 3 ឆ្នាំ ដែលតម្រូវឱ្យមានការចូលរួមជួយជាគំនិតយោបល់ពីអ្នកចូលរួម ដើម្បីធានាឱ្យថវិកា LCFF ត្រូវបានចំណាយដោយមានគោលបំណង និងវិធីសាស្រ្ត សំរាប់ចំនួនកូនសិស្សគោលដៅរបស់រដ្ឋ និងមូលដ្ឋាន ដូចជាកូនសិស្សដែលមានការខ្វះខាត, កូនសិស្សអ្នករៀនអង់គ្លេស, កូនសិស្សដែលជាកូនចិញ្ចឹម, កូនសិស្សពិការ, កូនសិស្សអាហ្វ្រិកអាមេរិកាំង និងកូនសិស្សឡាទីន។

នៅក្នុងឆ្នាំសិក្សា 2013-2014 សង្កាត់សាលារៀនអូកឡិនដ៍ បានទាក់ទាញបុគ្គលិក មាតាបិតា ប្រជាសហគមន៍ និងកូនសិស្សទាំងអស់បានចំនួន 5000 នាក់ ឱ្យមកចូលរួមបង្កើតផែនការ LCAP ដែលក្រុមប្រឹក្សាអប់រំរបស់យើង បានអនុម័តនៅក្នុងរដូវឈើលាស់ស្លឹកនៃឆ្នាំ 2014។ ការទទួលបានចំណេញនូវផលប្រយោជន៍ពីការជួយជាគំនិតយោបល់ នៅក្នុងដំណើរការដែលមានជាបន្តបន្ទាប់នេះ ត្រូវបានប្រើប្រាស់ ដើម្បីជួយដល់ការធ្វើកិច្ចសំរេចចិត្តក្នុងការផ្តល់ថវិកានៃសង្កាត់ និងដើម្បីរៀបចំធ្វើឱ្យគោលដៅប្រធានបទ និងវិធីសាស្រ្តនៃផែនការយុត្តិសាស្រ្តឱ្យមានលក្ខណៈទាន់សម័យ។

នៅពេលដែលយើងបង្កើតប្រព័ន្ធសាលារៀនលំដាប់ថ្នាក់ពិភពលោកហើយនោះ យើងនឹងបន្តដាក់បញ្ចូលនូវគុណតម្លៃនៃសហគមន៍; ប្រមូលទិន្នន័យសំខាន់ៗ; ផ្តល់ចំណុចជាគោលៗអំពីវិធានការជោគជ័យ និងរៀបចំឱ្យមានការប្តេជ្ញាចិត្តពីកូនសិស្សបុគ្គលិក និងក្រុមគ្រួសារ ដើម្បីដឹកនាំយើងក្នុងការបង្កើតសង្កាត់សាលារៀនមួយ ជាទីដែល ‹កូនសិស្សគ្រប់រូបចំរុងចំរើន!›។

# FROM CRADLE TO CAREER: **STEPS TO SUCCESS**

នៅក្នុងរយៈពេលចូលរួមស្តាប់មតិយោបល់របស់ខ្ញុំមក ជាញឹកញាប់ ខ្ញុំបានឮមាតាបិតាសួរជាសំណួរបែបនេះ ‹តើកូនរបស់ខ្ញុំត្រូវរៀនអំពីអ្វីខ្លះនៅពេលមកដល់ថ្នាក់ទី 5?› ឬ ‹ហេតុអ្វីបានជាកូនខ្ញុំត្រូវការចាំបាច់យកថ្នាក់ពីជគណិតនៅថ្នាក់ទី 8?› ចាប់ពីដើមកំណើតដល់ពេលរៀនចប់សាលាហៃស្កូល តើសេចក្តីប្រាថ្នាយ៉ាងតិចបំផុតដែលយើងចង់បានសំរាប់កូនសិស្សទាំងអស់នៃអូកឡិនដ៍នោះគឺអ្វីទៅ? នៅក្នុងគំនូរខាងក្រោមនេះ យើងផ្តល់ជូននូវច្រកផ្លូវដែលងាយយល់ ដើម្បីពន្យល់អំពីអ្វីៗដែលកូនសិស្សម្នាក់ៗត្រូវការដឹងនៅគ្រប់ដំណាក់ ដើម្បីត្រៀមខ្លួនជាស្រេចសំរាប់មហាវិទ្យាល័យ អាជីព និងសហគមន៍ ហើយនឹងមានជម្រើសពិតប្រាកដសំរាប់អនាគតរបស់ពួកគេ។

## ហេតុផលដែលសំខាន់

- រកប្រាក់បានច្រើនថែមទៀតក្នុងឆាកជីវិត
- មានបណ្តាញសំរាប់អាជីពរស់មួយជីវិត
- ធ្វើឱ្យគេចេះចូលរួមថែមទៀតក្នុងដំណើរការនៃប្រជាធិបតេយ្យ



កូនរបស់ខ្ញុំដែលរៀនថ្នាក់ទី 11 និងឬទី 12 ត្រូវការបញ្ចប់ថ្នាក់រៀនត្រៀមខ្លួនសំរាប់មាហាវិទ្យាល័យតាមតម្រូវការ ពី A ដល់ G; ទទួលបាននូវពិន្ទុតេស្តដែលអាចទទួលយកបានពីថ្នាក់កំរិតមហាវិទ្យាល័យ
យ៉ាងតិចបំផុតចំនួន 5 ថ្នាក់; បំពេញតាមស្តង់ដារសំរាប់មហាវិទ្យាល័យតាមកម្មវិធីវាយតម្លៃមុនពេលកំណត់ (EAP), តេស្តវាយតម្លៃលើការសិក្សា (SAT) និង/ឬ តេស្តមហាវិទ្យាល័យអាមេរិកាំង (ACT);
ចូលរួមក្នុងកម្មវិធីក្រៅការសិក្សា, សកម្មភាពតាមការងារ ឬសកម្មភាពចូលរួមការងារសង្គមក្នុងមួយឆ្នាំៗ; បំពេញគំរោងអប់រំផ្ទាល់ខ្លួន (PEP); និងវាយតម្លៃលើគន្លងនានា ដែលនាំឱ្យសំរេចបាននូវសញ្ញាប័ត្រ
កម្មតាមគោលដៅ និងសំរេចបានជោគជ័យ (ជាឧ. គ្រប់គ្រងពេលវេលា, ធនធានគ្រប់គ្រាន់, ការខិតខំព្យាយាម និងទំនុកចិត្ត) ដើម្បីធានាយ៉ាងណាឱ្យជម្រើសរបស់ពួកគេសំរាប់មហាវិទ្យាល័យ 4 ឆ្នាំ,
មហាវិទ្យាល័យ 2 ឆ្នាំ ឬកម្មវិធីរៀនវិជ្ជាជីវៈ; រៀនចប់ដោយទទួលបាននូវពិន្ទុគ្រេឌីតសំរាប់មហាវិទ្យាល័យ; មានកំណត់ហេតុប្រវត្តរូបដែលមានលក្ខណៈខ្លាំង; ចេះប្រកួតប្រជែងដើម្បីបានជំនួយ
និងអាហារូបត្ថម្ភ; និងត្រៀមខ្លួនឱ្យបានខ្លាំងជាងមុនក្នុងការបំរើជូនសង្គមវិញ។

កូនរបស់ខ្ញុំដែលរៀនថ្នាក់ទី 9 និងឬទី 10 ត្រូវការយកថ្នាក់រៀនត្រៀមខ្លួនជាស្រេចតាមតម្រូវការពី A ដល់ G សំរាប់មហាវិទ្យាល័យ; ចេះអានឱ្យបានស្មើ ឬខ្ពស់ជាងកំរិតថ្នាក់ខ្លួន; ចូលរួមក្នុងកម្មវិធីសិក្សា
Linked Learning; បន្តអនុវត្តតាមគំរោងអប់រំផ្ទាល់ខ្លួន (PEP); និងដឹងអំពីសញ្ញាប្រាប់ដោយពាក្យសំដី ដោយកាយ និងតាមកាលៈទេសៈ ដែលបញ្ជាក់ពីរបៀបមនុស្សផ្សេងៗទៀតគិតក្នុងចិត្ត ដើម្បីឱ្យសំ
រេចបានតាមពេលកំណត់ដែលត្រូវរៀនចប់សាលាហៃស្កូល, យកថ្នាក់រៀនកំរិតមហាវិទ្យាល័យជាច្រើនថ្នាក់នៅសាលាហៃស្កូល និងមានជម្រើសជាច្រើនទៀតក្នុងការជ្រើសយកថ្នាក់ដោយខ្លួនឯង។

កូនរបស់ខ្ញុំដែលរៀនថ្នាក់ទី 8 និងឬទី 9 ត្រូវការទទួលបាននូវពិន្ទុ A, B ឬ C ពីថ្នាក់ពីជគណិត និងពីថ្នាក់ភាសាសាស្ត្រ; មិនត្រូវខានមករៀនឱ្យលើស 5 ថ្ងៃនៃថ្ងៃរៀនទេ; បន្តរៀបចំគំរោងអប់រំផ្ទាល់ខ្លួន (PEP); និង
វាយតម្លៃលើការប្រតិកម្មតាមអារម្មណ៍នៅក្នុងស្ថានភាពដ៏ពិបាកៗខុសៗគ្នា, ដឹងពីរបៀបប្រើវា និងខិតខំព្យាយាមឱ្យបានដល់ទីបំផុត ដើម្បីសំរេចបានតាមគំរោងសំរាប់មហាវិទ្យាល័យ នៅពេលទៅដល់ថ្នាក់ទី 11
និងឬទី 12, ត្រៀមខ្លួនជាស្រេចសំរាប់កម្មវិធីសិក្សា Linked Learning កំរិតមហាវិទ្យាល័យ និងកម្មវិធីបង្ហាញអាជីព, មានជម្រើសច្រើនថែមទៀតក្នុងការយកថ្នាក់រៀន និងត្រៀមខ្លួនជា
ស្រេចសំរាប់ថ្នាក់រៀនតាមតម្រូវការពី A ដល់ G សំរាប់មហាវិទ្យាល័យ។

កូនរបស់ខ្ញុំដែលរៀនថ្នាក់ទី 5 និងឬទី 6 ត្រូវការចេះអាន និងចេះធ្វើលេខបានស្មើ ឬខ្ពស់ជាងកំរិតថ្នាក់របស់ពួកគេ, មិនត្រូវខានមករៀនឱ្យលើស 9 ថ្ងៃនៃថ្ងៃរៀនទេ, ចាប់ផ្តើមរៀប
គំរោងសិក្សាផ្ទាល់ខ្លួន (PEP), ខិតខំព្យាយាមបំពេញកិច្ចការដែលពិបាកៗ និងចេះបង្ហាញអាកប្បកិរិយាដែលចេះប្រតិបត្តិតាមនៅក្នុងក្រុម (ជាឧ. ចេះស្តាប់, ចេះលើកទឹកចិត្ត,
ចេះទទួលយកមតិយោបល់, ចេះសម្របសម្រួលចិត្តគ្នា, ចេះសម្របមតិគ្នា ដើម្បីត្រៀមខ្លួនក្នុងការទទួលបានជោគជ័យពីសាលាមធ្យមសិក្សា និងសាលាហៃស្កូល, មានជម្រើសច្រើនថែមទៀត
ក្នុងការយកថ្នាក់រៀន និងត្រៀមខ្លួនជាស្រេចសំរាប់កម្មវិធីសិក្សា Linked Learning កំរិតមហាវិទ្យាល័យ និងកម្មវិធីបង្ហាញអាជីព។

កូនរបស់ខ្ញុំដែលរៀនថ្នាក់ទី 2 និងឬទី 3 ត្រូវការចេះអាន និងចេះធ្វើលេខបានស្មើ ឬខ្ពស់ជាងកំរិតថ្នាក់របស់ពួកគេ, មិនត្រូវខានមករៀនឱ្យលើស
9 ថ្ងៃនៃថ្ងៃរៀនទេ, ខិតខំព្យាយាមបំពេញកិច្ចការដែលពិបាកៗ និងដឹងអំពីជំហាននានាដែលត្រូវការចាំបាច់ដើម្បីបំពេញកិច្ចការធំមួយ
ឬដើម្បីសំរេចគោលដៅ (ជាឧ. ដើម្បីជោគជ័យក្នុងការសិក្សា, ជោគជ័យផ្ទាល់ខ្លួន, ការប្រព្រឹត្តក្នុងថ្នាក់រៀន) ដើម្បីត្រៀមខ្លួនទទួលបានជោគជ័
យពីដើមដល់ចប់ក្នុងការសិក្សា, ច្រើនរៀនចប់ពីសាលាហៃស្កូលទាន់ពេលកំណត់ និងយកថ្នាក់រៀន និងមុខវិជ្ជាជ្រើសរើសដោយខ្លួនឯ
ងកំរិតសាលាមធ្យមសិក្សា ដែលធ្វើឱ្យពួកគេកាន់តែខិតខំអស់ពីសមត្ថភាព។

ហេតុអ្វីបានជាកូនរបស់ខ្ញុំ ចាប់ពីអាយុ 0-5 ឆ្នាំ ត្រូវការដឹងពាក្យប្រើប្រាស់ធម្មតាឱ្យបាន 100 ពាក្យ,
មិនត្រូវខានមករៀនឱ្យលើស 9 ថ្ងៃនៃថ្ងៃរៀនទេ, ត្រូវចេះគ្រប់គ្រងលើខ្លួនឯង, មើលឃើញបុគ្គលិកលក្ខណៈ និ
ងសមត្ថភាពខ្លួនក្នុងផ្លូវវិជ្ជមាន, ចេះប្រើពាក្យ និងពោលអះអាងប្រាប់យ៉ាងម៉ឺងម៉ាត់ពីចំណង់ចំណូលចិត្ត
និងអ្វីៗដែលខ្លួនប្រាថ្នាចង់បាន ក្នុងការត្រៀមខ្លួនជាស្រេចដើម្បីជោគជ័យពីថ្នាក់មតេយ្យផ្ទិន។



# កូនសិស្សគ្រប់រូបចំរុងចំរើន!








## ស្ថិតិប្រជាជននៃសង្កាត់សាលារៀនអូកឡិនដ៍ ឆ្នាំ 2014-2015

| | |
|---|---|
| ចំនួនចុះឈ្មោះរៀនសរុប | **48,181** |
| ស្លាលារៀនសហគមន៍នៃសង្កាត់សាលារៀនអូកឡិនដ៍ | 37,147 |
| សាលារៀនឆាធៀរនៃសង្កាត់សាលារៀនអូកឡិនដ៍ | 11,034 |
| ចំនួននិយោជិកសរុប (ស្លាលារៀនសហគមន៍នៃសង្កាត់សាលារៀនអូកឡិនដ៍) | 4,457 |

| | |
|---|---|
| ចំនួនសាលារៀនសរុប | **118** |
| ស្លាលារៀនសហគមន៍នៃសង្កាត់សាលារៀនអូកឡិនដ៍ | 86 |
| សាលារៀនឆាធៀរនៃសង្កាត់សាលារៀនអូកឡិនដ៍ | 32 |

## ប្រជាសាស្រ្ត

| សាលារៀនសហគមន៍នៃសង្កាត់សាលារៀនអូកឡិនដ៍ ថ្នាក់ **TK-12** | |
|---|---|
| ជនជាតិអាហ្វ្រិកអាមេរិកាំង | 30% |
| ជនជាតិអាស៊ី | 14% |
| ជនជាតិឡាទីន | 39% |
| ជនជាតិស្បែកស | 12% |
| ជនជាតិផ្សេងទៀត | 5% |
| អ្នករៀនអង់គ្លេស | 31% |
| អ្នកទទួលអាហារដោយឥតគិតថ្លៃ ឬតាមការបញ្ចុះថ្លៃ | 71% |
| កូនសិស្សជាកូនចិញ្ចឹម | 1% |
| កូនសិស្សអប់រំពិសេស | 10% |

| សាលារៀនឆាធៀរនៃសង្កាត់សាលារៀនអូកឡិនដ៍ ថ្នាក់ **K-12** | |
|---|---|
| ជនជាតិអាហ្វ្រិកអាមេរិកាំង | 21% |
| ជនជាតិអាស៊ី | 11% |
| ជនជាតិឡាទីន | 57% |
| ជនជាតិស្បែកស | 6% |
| ជនជាតិផ្សេងទៀត | 6% |
| អ្នករៀនអង់គ្លេស | 30% |
| អ្នកទទួលអាហារដោយឥតគិតថ្លៃ ឬតាមការបញ្ចុះថ្លៃ | 76% |

## អត្រារៀនចប់សាលាហៃស្គូលនៃសង្កាត់សាលារៀនអូកឡិនដ៍ ឆ្នាំ 2013*

| សាលារៀនសហគមន៍នៃសង្កាត់សាលារៀនអូកឡិនដ៍ ឆ្នាំ **2013** | |
|---|---|
| កូនសិស្សទាំងអស់ | 67% |

| ស្លាលារៀនឆាតធៀស្គូល **(Charter School)** នៃសង្កាត់សាលារៀនអូកឡិនដ៍ ឆ្នាំ **2013** | |
|---|---|
| កូនសិស្សទាំងអស់ | 72% |

## ថវិកានៃសាលារៀនសហគមន៍នៃសង្កាត់សាលារៀនអូកឡិនដ៍

| | |
|---|---|
| ការចំណាយថវិកាសរុប | $607.7 million |
| មានកំហិត | $284.8 million |
| គ្មានកំហិត | $322.9 million |

## ការលៃទុកថវិកាគ្មានកំហិត (2014-15)

| | |
|---|---|
| តម្រង់ទៅឱ្យសាលារៀននានា | $196.7 million (61 percent) |
| ការទ្រទ្រង់សាលារៀន | $82.2 million (25 percent) |
| ហេដ្ឋារចនាសម្ព័ន្ធ | $38 million (12 percent) |
| ប្រាក់កម្ចីពីរដ្ឋ | $6 million (2 percent) |

* កូនសិស្សណាដែលបានរៀនចប់សាលាហៃស្គូល ក្នុងរយៈពេលបួនឆ្នាំចាប់ពីពេលបានចូលថ្នាក់ទី 9

## សមិទ្ធកម្មក្នុងពេលថ្មីៗនេះ

- នៅក្នុងរយៈពេលពីរឆ្នាំកន្លងទៅនេះ និយោកជិកនៃសង្កាត់សាលារៀនអូកឡិនដ៍ ត្រូវបានតែងតាំងជាគ្រូបង្រៀនគំរូប្រចាំឆ្នាំនៃរដ្ឋកាលីហ្វូនញ៉ា (I'Asha Warfield, 2013) ហើយ និងជានិយោជិកគំរូប្រចាំឆ្នាំនៃរដ្ឋកាលីហ្វូនញ៉ាដែលជាបុគ្គលិកឥតត្រូវការសញ្ញាប័ត្រ (Marcus Board, 2014)។
- ចាប់តាំងពីឆ្នាំ 2010 មក សាលារៀនចំនួនបីនៃសង្កាត់សាលារៀនអូកឡិនដ៍ ទទួលបាននូវរង្វាន់កិត្តិយសថ្នាក់ជាតិ ហើយសាលារៀនចំនួន 10 ទៀត ត្រូវបានទទួលស្គាល់ថាជាសាលារៀនរដ្ឋកាលីហ្វូនញ៉ា ដែលទទួលបាននូវរង្វាន់។
- នៅចន្លោះឆ្នាំ 2011 និងឆ្នាំ 2013 អត្រានៃការរៀនចប់ពីសាលារៀននៃសង្កាត់សាលារៀនអូកឡិនដ៍ គឺមានភាពប្រសើរឡើងបាន 8.1 ភាគរយ ខណៈដែលអត្រានៃកូនសិស្សដែលបានបោះបង់ចោលសាលារៀនធ្លាក់ចុះដល់ 9.0 ភាគរយ។
- សង្កាត់សាលារៀនអូកឡិនដ៍ (OUSD) បានបើកគ្លីនិកសុខភាពនៅតាមទីសាលារៀនចំនួន 15 កន្លែង ដែលមានច្រើនជាងគេបំផុតសំរាប់មនុស្សម្នាក់ៗ បើប្រៀបធៀបនឹងសង្កាត់សាលារៀនផ្សេងៗទៀតទាំងអស់ក្នុងប្រទេស។
- សង្កាត់សាលារៀនអូកឡិនដ៍ គាំទ្រគោលដៅនៃកម្មវិធីត្រៀមខ្លួនសំរាប់មហាវិទ្យាល័យ និងអាជីពរបស់ខ្លួន ជាមួយនឹងវិទ្យាគារភាគច្រើននៃកាលីហ្វូនញ៉ា ជាងសង្កាត់សាលារៀនណាៗទាំងអស់ក្នុងរដ្ឋ។
- អូកឡិនដ៍ គឺជាសង្កាត់សាលារៀនមួយ ក្នុងចំណោមតែសង្កាត់សាលារៀនចំនួនប្រាំបីក្នុងប្រទេស ដែលត្រូវបានជ្រើសរើស ឱ្យចូលរួមក្នុងកម្មវិធីសហការផ្តួចផ្តើមគំនិតពិសេសនៃសង្កាត់ដែលបានឧបត្ថម្ភឡើង ដោយកម្មវិធីសហការសំរាប់ការរៀនសូត្រអំពីកម្មវិធីសិក្សាមុខវិជ្ជាសិក្សា សង្គម និងអារម្មណ៍ (CASEL) ដើម្បីជួយកូនសិស្សក្នុងការគ្រប់គ្រងអារម្មណ៍ ការសំរេចបាននូវគោលដៅវិជ្ជមាន ការចេះយល់ចិត្តមនុស្សដទៃ ការចេះរក្សាទំនាក់ទំនងល្អ និងការចេះធ្វើកិច្ចសំរេចចិត្តដោយមានការទទួលខុសត្រូវ។

កត្តាសម្ងាត់របស់យើង—ពុំមែនជារឿងសម្ងាត់អ្វីណាស់ណានោះទេ—គឺជំនាញប្រកបដោយវិជ្ជាជីវៈ និងការបូជាកម្លាំងកាយនៃសមាជិកម្នាក់ៗនៃបុគ្គលិករបស់យើងដែលមានសញ្ញាប័ត្រ និងគ្មានសញ្ញាប័ត្រ។ លោកអ្នកឃើញទេ ត្រង់ហ្នឹងហើយ ជាទីដែលយើងនឹងទទួលបាននូវជោគជ័យ។ យើងច្បាស់ជានឹងមានការមិនចុះសម្រុងនឹងគ្នាមែន ប៉ុន្តែយើងមិនត្រូវបណ្ដោយឱ្យរឿងទាំងហ្នឹងធ្វើឱ្យបែកបាក់គ្នា និងធ្វើឱ្យយើងហែកហួរប្រឈមមុខដាក់គ្នាក្នុងលក្ខណៈរំខានទេ; បើសិនជាយើងជឿជាក់លើគ្នាទៅវិញទៅមក ហើយនិងប្រកាន់យកនូវប្រយោជន៍រួម ដើម្បីកូនៗរបស់យើង; បើសិនជាយើងមិនធ្វើអ្វីមួយដែលបំផ្លាញដល់ការមានឱកាសក្នុងការរៀនសូត្ររបស់កូនៗនៃយើង; បើសិនជាយើងទាំងអស់គ្នាទោះជាមានការខ្វែងគំនិតគ្នាយ៉ាងណាក៏ដោយ មានបំណងចង់ធ្វើការដោះស្រាយរួមគ្នាក្នុងនាមជាអ្នកមានវិជ្ជាជីវៈ និងជាមនុស្សចាស់ចិត្តចាស់គំនិត; បើសិនជាយើងនឹងមិនធ្វើឱ្យកូនៗរបស់យើងរងទុក្ខលំបាក ទទឹមនឹងពេលដែលយើងនាំគ្នាធ្វើការដោះស្រាយបញ្ហានានាដែលយើងមានពិតមែននោះ យើងនឹងធ្វើឱ្យកម្មវិធីអប់រំរបស់យើងមានប្រសិទ្ធភាពបាន។ អញ្ចឹងទេ យើងត្រូវតែតាំងចិត្តថា ក្រោយពីពេលយើងបានជួយដល់កូនជំទង់ៗរបស់យើងមកស្លាកតូចៗទាំងនោះ ដែលពួកបានយកមកឱ្យយើងនោះនឹងពុំត្រូវបានសរសេរដាក់នៅលើវាថា ‹គុណាតម្លៃអន់, តម្លៃថោក› ឡើយ ប៉ុន្តែផ្ទុយទៅវិញ ដោយសារពួកគេចូលមករៀនក្នុងសាលារដ្ឋនៃក្រុងអូកឡិនដ៍; ដោយសារតែពួកគេបានជួបជាមួយនឹងលោកអ្នក ព្រមទាំងបានជាប់ទាក់ទិននឹងសាលារៀននៅទូទាំងទីក្រុង; ពួកគេនឹងមានសំណោរនៅលើស្លាកតូចៗរបស់ពួកគេថា ‹មានតម្លៃខ្ពស់ជាងគេ, គុណាតម្លៃកើនឡើងខ្ពស់›។ លោកបណ្ឌិត

— DR. MARCUS FOSTER
អគ្គនាយកនៃសង្កាត់សាលារៀន
សង្កាត់សាលារៀនអូកឡិនដ៍
1970 – 1973

OAKLAND UNIFIED
SCHOOL DISTRICT
សាលារៀនសហគមន៍, សិស្សានុសិស្សចំរុងចំរើន

1000 Broadway, Oakland, California 94607
ph 510.434.7790 | www.ousd.k12.ca.us

© 2014 OAKLAND UNIFIED SCHOOL DISTRICT. PHOTOS: HASAIN RASHEED.